## ការបើកសាលាជាតំណាក់ៗឱ្យសិស្សមករៀនជាធម្មតា គ្រោងបើកនៅថ្ងៃទី២៩ខែមិនា

សហគមន៍សាលារៀនក្នុងក្រសួងអប់រំឡុងប៊ីចជាទីមេត្រី,

ក្រោយពីរយៈពេលជាងមួយឆ្នាំនៃការសិក្សាតាមអនទ្បាញដោយសារតែការរាតត្បាតសកលនៃរោគកូវីដ-១៩ យើងមានសេចក្តីរីករាយដោយប្រកាសថាក្រសួងអប់រំឡុងប៊ីច LBUSD គ្រោងចាប់ផ្តើមបើកសាលាជាតំណាក់ៗឱ្យសិស្សទៅរៀនតាមធម្មតាវិញ នៅថ្ងៃទី២៩ខែមិនា។

### ថ្នាក់ទាបៗចាប់ផ្តើមមុន

សិស្សដែលត្រឡប់ទៅរៀននៅសាលានៅថ្ងៃទី២៩ខែមិនាគឺសិស្សពីកំរិតថ្នាក់អន្តរមត្តេយ្យ(TK) ដល់ថ្នាក់ទី៥ ដែលមាតាបិតាបានជ្រើសរើសតារាងវេលាសិក្សាប្រភេទហាយប្រ៊ីឌ(ពាក់កណ្តាលនៅសាលាពាក់កណ្តាលនៅផ្ទះ)។ មាតាបិតាដែលចង់ឱ្យកូនគាត់បន្តរៀនទាំងស្រុងតាមអនទ្បាញ អាចបន្តរៀនតាមជំរើសនោះតទៅទៀត។

ការត្រឡប់ទៅរៀននៅសាលាវិញនៃសិស្សថ្នាក់អន្តរមត្តេយ្យដល់ទី៥ (TK-5) សន្មតថាអត្រាករណីកូវីឌនៅក្នុង ខោនធីឡូសអ៊ិនជើលេសនៅមានកំរិតក្រោម២៥ករណីលើ១០០០០០នាក់ ដូចដែលបានបញ្ជាក់ដោយការណែនាំថ្មីៗរបស់ក្រសួងសុខាភិបាលសាធារណៈជនរដ្ឋកាលីហ្វ័រនីញ៉ា ស្តីពីការបើកសាលារៀនវិញ។ អត្រាករណីក្នុងសប្តាហ៍នេះបានធ្លាក់ចុះក្រោមកំរិតចាប់ផ្តើមនោះ ហើយបានធ្លាក់ចុះជាច្រើនក្នុងប៉ុន្មានសប្តាហ៍ថ្មីៗកន្លងមកនេះ។

ក្រសួងអប់រំឡុងប៊ីច LBUSD បន្តសហការជាមួយក្រសួងសុខាភិបាលក្រុងឡុងប៊ីចដើម្បីចាក់ថ្នាំបង្ការរោគកូវីឌ១៩ដល់បុគ្គលិកសាលាទាំងអស់។ បុគ្គលិក LBUSD រាប់ពាន់នាក់បានទទួល ការចាក់ថ្នាំបង្ការរោគនេះក្នុងប៉ុន្មានសប្តាហ៍ថ្មីៗកន្លងមកនេះ ដែលផ្តល់អាទិភាពដល់បុគ្គលិកដែលកិច្ចការរបស់គាត់គឺត្រូវជួបផ្ទាល់នឹងសាធារណៈជន និងគ្រូបង្រៀនក្នុងកំរិតថ្នាក់ទាបៗ។ គ្រូបង្រៀនកំរិតថ្នាក់ TK-5 នៅក្នុង LBUSD ដែលនឹងត្រឡប់ទៅបង្រៀននៅសាលាជាធម្មតាវិញនឹងត្រូវផ្តល់ឱ្យនូវការចាក់ថ្នាំ បង្ការរោគទាំងលើកទីមួយនិងលើកទីពីរ។ គ្រូបង្រៀនទាំងនោះនឹងវិលត្រឡប់ទៅសាលាវិញនៅថ្ងៃទី២២ខែមិនាដើម្បីរៀបចំថ្នាក់រៀនសម្រាប់សិស្សដែលវិលត្រឡប់មករៀននៅសាលា ស្របពេលដែលការរៀនសូត្រតាមអនទ្បាញនឹងបន្តធ្វើទៀត។

### កំរិតអនុវិទ្យាល័យនិងវិទ្យាល័យ

លក្ខណៈវិនិច្ឆ័យសុខភាពសាធារណៈរបស់រដ្ឋកាលីហ្វ័រនីញ៉ា មានភាពតឹងរ៉ឹងជាងកំរិតបឋមសិក្សា សម្រាប់ការបើកឡើងវិញនូវកំរិតអនុវិទ្យាល័យនិងវិទ្យាល័យ។ កំរិតអនុវិទ្យាល័យនិងវិទ្យាល័យអាចបើកឱ្យសិស្សត្រឡប់ទៅរៀននៅសាលាវិញបើខោនធីស្ថិតនៅក្នុងកំរិត "ពណ៌ក្រហម" នៃការកំណត់របស់រដ្ឋ ឱ្យបានយ៉ាងតិច៥ថ្ងៃជាប់គ្នា។ ក្នុងកំរិតព៌ណក្រហមនេះ អត្រាករណីមធ្យមក្នុងកំឡុងរយៈពេល៧ថ្ងៃគឺចន្លោះ៤និង៧លើ១០០០០០នាក់ ហើយចំនួនមនុស្សដែលបានធ្វើតែសមានលទ្ធផលវិជ្ជមានក្នុងកំឡុងរយៈពេល៧ថ្ងៃជាមធ្យមគឺចន្លោះ 5% និង 8% ។ ដូចគ្នានឹងកំរិតសាលាបឋមសិក្សាដែរ ការវិលត្រឡប់ទៅរៀននៅសាលាវិញនេះត្រូវបានផ្តល់ឱ្យប៉ុន្តែមិនមែនជាការតម្រូវចាំបាច់ទេ នៅពេលដែលការបើកសាលានេះត្រូវបានអនុញ្ញាតដោយរដ្ឋ។ សិស្សនឹងមានជំរើស បន្តរៀនតាមអនទ្បាញ ឬរៀននៅសាលាតាមតារាងវេលាហាយប្រ៊ីឌ។

សន្មតថាខោនធីឡូសអ៊ិនជើលេសស្ថិតនៅក្នុងស្ថានភាពតាមលក្ខណៈវិនិច្ឆ័យសុខភាពសាធារណៈជនរបស់រដ្ឋ ការវិលត្រឡប់ទៅរៀននៅសាលាតាមតារាងវេលាហាយប្រ៊ីឌរបស់អនុវិទ្យាល័យនិងវិទ្យាល័យ នឹងចាប់ផ្តើមកាលវេលាក្រោមនេះៈ

- ថ្ងៃទី២០ខែមេសា - ថ្នាក់ទី១២ និងថ្នាក់ទី៦ដល់ទីថ្នាក់៨
- ថ្ងៃទី២៦ខែមេសា - ថ្នាក់ទី៩ដល់ទី១១

គ្រូបង្រៀនសាលាអនុវិទ្យាល័យនិងវិទ្យាល័យនឹងត្រឡប់ទៅសាលារៀនវិញនៅថ្ងៃទី១២ខែមេសាដើម្បីរៀបចំថ្នាក់រៀនសម្រាប់សិស្សដែលវិលត្រឡប់មករៀននៅសាលា ស្របពេលដែលការរៀនសូត្រតាមអនឡាញនឹងបន្តធ្វើទៀត។

## ការកែធ្វើឱ្យប្រសើរឡើងនូវសុខភាពនិងសុវត្ថិភាពនៅក្នុងបរិយាកាសិក្សាហាយប្រ៊ីឌ

សុវត្ថិភាពរបស់បុគ្គលិកនិងសិស្សានុសិស្សគឺជាអាទិភាពដំបូងរបស់ក្រសួងអប់រំ។ នៅក្នុងអំឡុងពេល នៃខែកុម្ភៈ ក្រសួងអប់រំបានផ្តល់ឱ្យនូវបច្ចុប្បន្នភាពនិងព័ត៌មាន រួមទាំងមានវីដេអូផងដែរ អំពីសភាពនៃថ្នាក់រៀនជាមួយការដាក់គម្លាតឆ្ងាយពីគ្នា ការសំអាតសម្លាប់មេរោគ និងវិធានការណ៍សុវត្ថិភាពផ្សេងៗ ទៀត។ សូមមើលត្រង់នេះជាឧទាហរណ៍ ( View an example here) .

ការសំអាតពេញលេញ ការរក្សាអនាម័យ និងការសម្លាប់មេរោគក្នុងថ្នាក់រៀននឹងត្រូវធ្វើទៅជាប្រចាំថ្ងៃ ហើយការហ្វឹកហ្វឺនពីសុខភាពនិងសុវត្ថិភាពត្រូវបានផ្តល់ឱ្យដល់អ្នកដឹកនាំសាលា។

## ការធ្វើឱ្យប្រសើរឡើងផ្នែកសុខភាពផ្សេងបន្ថែមទៀត

- សិស្សដែលត្រឡប់ទៅរៀននៅសាលាវិញនឹងត្រូវទទួលការឆែកពិនិត្យសុខភាពជារៀងរាល់ថ្ងៃ ក៏ដូចគ្នានឹងបុគ្គលិកសាលាផងដែរ។
- សិស្សនឹងត្រូវតម្រូវឱ្យពាក់របាំងមុខ។ តុសិស្សនឹងត្រូវដាក់ចម្ងាយ៦ហ្វីទ(២ម៉ែត្រ)ពីគ្នា។
- សិស្សនៅសាលាបឋមសិក្សានឹងស្ថិតនៅក្នុងថ្នាក់ឬក្រុមរបស់ខ្លួនជាមួយបុគ្គលិកសាលានៅពេលនៅសាលារៀន ដើម្បីកាត់បន្ថយការធ្វើអន្តរកម្មរវៀងមនុស្សនិងមនុស្សនៅសាលា។
- ការធ្វើតែសកូនវីឌសម្រាប់សិស្សនិងបុគ្គលិកសាលាត្រូវបានគ្រោងឡើង។

## ព័ត៌មានស្តីពីការធ្វើតែស្តកូវីឌ

ប្រសិនបើខោនធីឡូសអ៊ិនជើលេសនៅស្ថិតនៅក្នុងកំរិតពណ៌ស្វាយរឹតត្បិតបំផុត ដូចដែលបានកំណត់មកដោយរដ្ឋ បុគ្គលិកសាលានិងសិស្សទាំងអស់ដែលត្រឡប់ទៅរៀននៅសាលាជាធម្មតាវិញនឹងត្រូវ តម្រូវឱ្យចូលរួមក្នុងការធ្វើតែស្តដោយពុំមានរោគសញ្ញាជាប្រចាំសប្តាហ៍នៅសា ដោយតាមវិធីត្បាល់យកសំបោររន្ធច្រមុះទៅពិនិត្យ។ នេះគឺមានន័យថា ទោះបីជាសិស្សនិងបុគ្គលិកសាលាពុំមានបង្ហាញ រោគសញ្ញាកូវីឌក៏ដោយ ពួកគេត្រូវតែទទួលការធ្វើតែស្តនេះដែលជាវិធានការសុវត្ថិភាពបន្ថែម។ “Anterior nasal” គឺជាផ្នែកនៅខាងមុខនៃរន្ធច្រមុះ។ ការត្បាល់រន្ធច្រមុះរបៀបនេះមានភាពលុកលុយតិចជាងវិធីធ្វើតែស្ត ផ្សេងទៀតដែលត្រូវរុកចូលជ្រៅទៅផ្នែកខាងក្រោយនៃរន្ធច្រមុះ។ នៅពេលណាខោនធីឡូសអ៊ិនជើលេស

ស្ថិតនៅក្នុងកំរិតមានភាពរឹតត្បិតតិចជាង ការធ្វើតេស្តអាចត្រូវកាត់បន្ថយឬឈប់ធ្វើតែម្តង។ ព័ត៌មានលំអិតចុងក្រោយដែលទាក់ទងនឹងការធ្វើតេស្តរបៀបនេះនឹងត្រូវផ្តល់ជាដំណឹងនៅពេលណាយើងមាននូវព័ត៌មាននោះ។

## សេវាកម្មផ្តល់ឱ្យផ្ទាល់នៅសាលាដែលមានរួចមកហើយ

ដោយប្រើវិធីការសុខភាពនិងសុវត្ថិភាពជាច្រើនន័យ៉ាងដូចដែលបានពណ៌នាមកខាងលើនេះ ក្នុងរយៈប៉ុន្មានខែថ្មីៗកន្លងមកនេះ ក្រសួងអប់រំ LBUSD បានផ្តល់ឱ្យដោយជោគជ័យនូវការរៀនសូត្រផ្ទាល់នៅសាលាជាមួយសិស្សថ្នាក់មុនចូលសាលា (ព្រីស្គូល) និងការមើលថៃទាំកុមារ នៅក្នុងពេលរាតត្បាតសកល បំរើដល់កុមារជាង១៦០០នាក់ដែលជាកូនរបស់អ្នកធ្វើការជួរមុខសំខាន់ នៅក្នុងមជ្ឈៈមណ្ឌលបណ្តុះបណ្តាលកុមារនិង យិឌក្លឹប និងនៅសាលា ហ៊ែឌស្តាត។ សូមទស្សនាវីដេអូ។ **View video**.

## ព័ត៌មានបន្ថែមទៀត

សូមចូលទៅគេហទំព័រ lbschools.net/coronavirus ដើម្បីបច្ចុប្បន្នភាពថ្មីៗនិងពីគម្រោងបើកសាលានិងគម្រោងសុវត្ថិភាពរបស់ក្រសួងអប់រំឡុងប៊ីច ដែលមានបញ្ចូលនូវព័ត៌មានបន្ថែមពីវិធីការលើសុខភាពនិងសុវត្ថិភាព ព័ត៌មានថ្មីៗអំពីកូវីឌ១៩ ការសំអាតនិងសម្លាប់មេរោគក្នុងអគារសាលារៀន កម្មវិធីបង្ហាត់បង្រៀន ការអប់រំពិសេសនិងសុខភាពផ្លូវចិត្ត ហើយនិងកម្មវិធីបន្ថែមក្រៅម៉ោងសិក្សានិងកីឡា។ គម្រោងនេះត្រូវបានចុះផ្សាយដំបូងកាលពីខែសីហា២០២០។ គម្រោងដែលបានកែធ្វើបច្ចុប្បន្នភាពនឹងត្រូវដាក់ចុះផ្សាយក្នុងពេលឆាប់ៗខាងមុខដែលឆ្លុះបញ្ចាំងលើព័ត៌មានបច្ចុប្បន្ន។

សូមអរគុណដល់អ្នករាល់គ្នា នៅក្នុងសហគមន៍សាលារៀនយើងដល់ការគាំទ្ររបស់លោកអ្នក ខណៈដែលយើងធ្វើការឆ្ពោះទៅអនាគតដែលមានភាពត្រចះត្រចង់ជាង។

ដោយក្តីស្មោះចំពោះ,

Jill

បណ្ឌិត Jill Baker អគ្គនាយកសាលារៀន